## ចំពោះជនបរទេសប្រចាំនៅកូរ៉េ ដែលបានរងការទុក្ខវេទនាជាមួយបញ្ហា ដូចជាការលែងលះ គ្នា
## ដែលបានកើតឡើងក្នុងការរស់នៅអាពាហ៍ពិពាហ៍ជាមួយជនជាតិកូរ៉េ តុលាការគ្រួសារ ខេគូ ជួយសង្គ្រោះ!

### ១. ចំពោះអ្នកដូចនេះ យើងណែនាំមេធាវីកំណត់ដែលអាចជួយសង្គ្រោះក្នុងការប្តឹង ដើម្បីជនបរទេស!

- ជនបរទេសដែលកំពុងស្នាក់នៅកូរ៉េ ឬជនអន្តោប្រវេសន៍ដែលមិនចេះស្ទាត់ភាសាកូរ៉េ
- អ្នកដែលមិនប្រាកដថាចាញ់ក្តី
- អ្នកដែលខ្វះសមត្ថភាពខាងប្រាក់ដែលនឹងបង់ថ្លៃឈ្នួលមេធាវី

### ២. មេធាវីកំណត់ដែលអាចជួយសង្គ្រោះក្នុងការប្តឹង នឹងជួយលោកអ្នកយ៉ាងដូចនេះ។

- ដាក់ពាក្យសុំការសង្គ្រោះក្នុងការប្តឹង និងការប្រឹក្សាយោបល់ថាតើដាក់ពាក្យបណ្តឹងឬអត់
- កត់ត្រានិងដាក់ជូននូវពាក្យសុំការសង្គ្រោះក្នុងការប្តឹងនិងពាក្យបណ្តឹង
- កែតាមការផ្តល់អនុសាសន៍ឬបញ្ជាឲ្យកែពាក្យសុំការសង្គ្រោះក្នុងការប្តឹងឬពាក្យបណ្តឹងរបស់តុលាការ
- កិច្ចការងារនានាដែលត្រូវការចាំបាច់ក្នុងការប្តឹងនៅក្នុងករណីដែលត្រូវបានសម្រេចពីការសង្គ្រោះអំពីចំណាយលើសេវាមេធាវីទាំងអស់

### ៣. តើរង្វង់ដែលអាចទទួលការជួយសង្គ្រោះក្នុងការប្តឹងបាននោះរហូតដល់ណា?

- ថ្លៃតែម(ពាក្យបណ្តឹង, ពាក្យបណ្តឹងឧទ្ធរណ៍, ផ្សេងៗ)
- ចំណាយសេវាមេធាវី
- ផ្សេងៗ(ឧទាហរណ៍៖ បកប្រែភាសា បកប្រែឯកសារជាដើម)
- ចំណាយទាំងអស់ក្នុងការប្តឹងរួមទាំងខ្លឹមសារខាងលើ

### ៤.អំពីរឿងដែលមិនមានវិធានការតាមនីតិវិធីបណ្តឹង ក៏លោកអ្នកអាចទទួលជំនួយតាមការជួយសង្គ្រោះនីតិវិធីបានដែរ!

ដើម្បីអ្នកដែលខ្វះសមត្ថភាពខាងប្រាក់ដែលនឹងបង់ថ្លៃចំណាយក្នុងការធ្វើនីតិវិធីបណ្តឹង ឬមានវិបត្តិពិតប្រាកដក្នុងការរស់នៅដោយសារការបង់ថ្លៃនោះ យើងជួយផ្តល់ ឬដាក់ពាក្យសុំថ្លៃតែម ថ្លៃផ្ញើ ថ្លៃសេវាមេធាវី ចំណាយវាយតម្លៃជាដើម ដោយការសម្រេចរបស់តុលាការ។

### ៥. នៅទីណា គេណែនាំពីពាក្យសុំការជួយសង្គ្រោះក្នុងការប្តឹងទេ?

ទីកន្លែង ៖
ការិយាល័យច្រកចេញចូលសម្រាប់ជនបរទេសនៅបន្ទប់ប្រជាពលរដ្ឋនៅជាន់ទទួលភ្ញៀវក្នុងតុលាការគ្រួសារក្រុងសេអ៊ូល

លេខទូរស័ព្ទ ៖ 02 - 2055 – 7165

ពេលម៉ោងធ្វើការ ៖ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ , ម៉ោង9 ~ 18